ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ :......១១៣......បទ..........

ភ្នំពេញ ថ្ងៃទី២៦ ខែ មេសា ឆ្នាំ ២០០២

# ប្រកាស

# ស្តីពីការតភ្ជាប់រវាងប្រព័ន្ធទូរស័ព្ទ

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស រកត ១១៩៨ ៧២ចុះថ្ងៃទី៣០ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាព រាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២.នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រម នសរកម ០១៩៦-២០ ចុះថ្ងៃទី ២៤ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។
- បានឃើញអនុក្រឹត្យលេខ៦៦ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។
- បានឃើញសេចក្តីសំរេចលេខ ១៩៤ សសរ ចុះថ្ងៃទី ១១-១២-៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីស្តីពីឋានានុក្រមគ្រប់គ្រងតម្លៃ ។
- បានឃើញអនុសាសន៍ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងលិខិតលេខ១៣០០សហវចុះថ្ងៃទី៣មេសាឆ្នាំ២០០២ ។
- បានឃើញសេចក្តីសម្រេចរបស់អង្គប្រជុំ នៃ ក្រសួងប.ទ.ជាមួយប្រតិបត្តិករទាំងអស់និងនាថ្ងៃទី ២៩.៤.០២ ។

## សម្រេច

### ១- និយមន័យ

នៅក្នុងបទបញ្ញត្តិនេះ :

១.១ និយ័តករ (Regulator) គឺជាក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដែលមានភារកិច្ចបង្កើតនិងអនុវត្តបទបញ្ញត្តិក្នុងវិស័យទូរគមនាគមន៍។

១.២ គណនេយ្យផ្ទាល់ (Direct Accounting) មានន័យថាការទូទាត់ប្រាក់ដែលត្រូវធ្វើដោយផ្ទាល់រវាងបណ្តាញបញ្ជូនដើមនិងបណ្តាញទទួល។

១.៣ ប្រតិបត្តិករ (Network Operator) មានន័យថាអង្គភាពដែលមានអាជ្ញាប័ណ្ណគ្រប់គ្រងនិងផ្តល់សេវាទូរគមនាគមន៍។

### ២- សេចក្តីតម្រូវការនៃការតភ្ជាប់ខ្សែបណ្តាញទូរស័ព្ទ

២.១- គ្រប់ប្រតិបត្តិករទាំងអស់មិនត្រូវធ្វើឱ្យមានការរាំងស្ទះដោយចេតនានូវចរន្តសេវាទូរស័ព្ទដែលហៅចេញពីប្រព័ន្ធរបស់ខ្លួន ឬហៅមកប្រព័ន្ធរបស់ខ្លួន ឬឆ្លងកាត់តាមប្រព័ន្ធរបស់ខ្លួនឡើយ លើកលែងតែបានទទួលសេចក្តីអនុញ្ញាតិជាលាយល័ក្ខណ៍ អក្សរពីនិយ័តករ។

២.២- ក្នុងករណីដែលប្រតិបត្តិករណាមិនព្រមបង់ថ្លៃតភ្ជាប់ទៅភាគីមួយទៀត ភាគីនោះអាចសុំការអនុញ្ញាតិពីនិយ័តករ បិទចរន្តសេវាជាមួយប្រតិបត្តករដែលមិនព្រមបង់នោះ។

២.៣- គ្រប់ប្រតិបត្តិករទាំងអស់ត្រូវបញ្ជូនលេខទូរស័ព្ទដែលហៅចេញ និងលេខទូរស័ព្ទដែលគេហៅចូល (A and B numbers) ទៅប្រព័ន្ធទូរស័ព្ទដែលទទួល។

២.៤- ប្រតិបត្តិករទាំងអស់ត្រូវរក្សាគុណភាពសេវាហៅចេញឬចូល ទៅឬមកពីបណ្តាញដទៃយ៉ាងហោចណាស់ឱ្យមានគុណភាពខ្ពស់ដូចក្នុងបណ្តាញរបស់ខ្លួន។

២.៥- ប្រព័ន្ធរបស់ក្រសួងប.ទ.ត្រូវយកធ្វើជាចំណុចឆ្លងកាត់ (Transit point) លុះណាតែមានសេចក្តីអនុញ្ញាតិជាថ្មី។

### ៣- ការផ្លាស់ប្តូរប្រព័ន្ធ

៣.១ ម្ចាស់ប្រព័ន្ធដែលមានបំណងកែប្រព័ន្ធដែលអាចតម្រូវឱ្យមានការកែប្រព័ន្ធប្រតិបត្តករដទៃ ត្រូវទទួលការឯកភាពពីគ្រប់ប្រតិបត្តករឯទៀត ហើយត្រូវជូន ដំណឹងជាលាយល័ក្ខណ៍អក្សរមកនិយ័តករ។ ក្នុងករណីពុំមាន

ការឯកភាពអំពីប្រតិបត្តិករដទៃ និយ័តករត្រូវសម្រេចអនុញ្ញាតិឬមិនអនុញ្ញាតិឱ្យធ្វើការកែប្រព័ន្ធហើយនិង ចង្អុលថាអ្នកណាជាអ្នកទទួលបន្ទុកលើថ្លៃកែនោះ យ៉ាងយូរ៦ខែគិតចាប់ពីថ្ងៃទទួលសំណើរ ។

## ៤- តម្លៃនៃការតភ្ជាប់

៤-១ វវាងប្រព័ន្ធក្នុងប្រទេសនិងក្នុងប្រទេស

៤-១-១ តម្លៃតភ្ជាប់រវាងប្រព័ន្ធចល័តនិងចល័តត្រូវស្មើនិង ៥.៨ សេន ក្នុង១ នាទី ។

៤-១-២ តម្លៃតភ្ជាប់រវាងប្រព័ន្ធចល័តនិងអចល័ត ទាំងទៅឬមក ត្រូវស្មើនិង ២ សេន ក្នុង១ នាទី ។

៤-១-៣ តម្លៃតភ្ជាប់រវាងប្រព័ន្ធអចល័តនិងអចល័តក្នុងដំបន់តែមួយ (In same area) ឬឆ្លងដំបន់ (Across areas) ហើយដំបន់ទាំងពីរនោះផ្សេងពីភ្នំពេញ ត្រូវស្មើនិង ១ សេន ក្នុង១ នាទី ។

៤-១-៤ តម្លៃតភ្ជាប់រវាងប្រព័ន្ធអចល័តនិងអចល័តពីភ្នំពេញទៅដំបន់ផ្សេង ត្រូវស្មើនិង ២ សេន ក្នុង១ នាទី ។

៤-១-៥ តម្លៃតភ្ជាប់រវាងប្រព័ន្ធអចល័តនិងអចល័តពីដំបន់ផ្សេងមកភ្នំពេញ ត្រូវស្មើនិង ១ សេន ក្នុង១ នាទី ។

៤-២ រវាងប្រព័ន្ធក្នុងប្រទេសនិងប្រព័ន្ធអន្តរជាតិ

៤-២-១ តម្លៃតភ្ជាប់រវាងមាត់ច្រកអន្តរជាតិនឹងប្រព័ន្ធក្នុងប្រទេសត្រូវបានកំណត់ដូចតទៅ :

- ការហៅចូលពីបរទេស : ប្រព័ន្ធមាត់ច្រកអន្តរជាតិត្រូវបង់ឱ្យប្រព័ន្ធក្នុងប្រទេស ២សេនក្នុង ១នាទី ។
- ការហៅចេញទៅបរទេស : ប្រព័ន្ធក្នុងប្រទេសត្រូវបង់ឱ្យប្រព័ន្ធមាត់ច្រកអន្តរជាតិ ១០០% នៃតម្លៃហៅចេញរបស់មាត់ច្រកអន្តរជាតិ ។

៤-៣ តម្លៃឆ្លងកាត់ប្រព័ន្ធក្រសួងប.ទ.

៤-៣-១តម្លៃឆ្លងកាត់ប្រព័ន្ធនៃក្រសួងប.ទ. ត្រូវស្មើនិង ១ សេន ក្នុង១នាទីលើកលែងតែ :

- ប្រព័ន្ធក្រសួងប.ទ.ជាអ្នក ទទួលចរន្តសេវានោះ ឬ
- ចរន្តសេវានោះជាការហៅចេញទៅឬចូលមកពីអន្តរជាតិ ។

៤-៤ តម្លៃនីយ័តករ

៤-៤-១ ប្រតិបត្តិករត្រូវបង់ប្រាក់ ០.៣ សេនក្នុង១នាទី សម្រាប់នីយ័តករ ចំពោះគ្រប់ចរន្តសេវាតភ្ជាប់រវាងប្រព័ន្ធ ។

## ៥ ការកត់ត្រាទិន្នន័យ និងការទូទាត់ប្រាក់

៥-១ ចំនួននាទីដែលត្រូវទូទាត់ត្រូវគិតអំពីពេលដែលគេលើកទទួលរហូតត្រឹមពេលភាគីណាមួយដាក់ចុះ ។

៥-២ ចំនួននាទីសរុបត្រូវគិតលំអិតតាមចំនួនវិនាទីនៃការហៅសរុបទាំងអស់លើកលែងតែការហៅទៅអន្តរជាតិ ដែលគិត១៥វិនាទីម្តង ។

៥-៣ រយៈពេលចាក់សម្លេងផ្តល់ជាពតិមានដល់អតិថិជនមិនត្រូវរាប់បញ្ចូលក្នុងការគិតប្រាក់ឡើយ ។

៥-៤ គ្រប់ប្រតិបត្តិករត្រូវផ្តល់ចំនួននាទីសន្ទនាចូលនិងចេញប្រព័ន្ធខ្លួនទៅភាគីមួយទៀតដើម្បីធ្វើការទូទាត់ ។

៥-៥ ប្រតិបត្តិករត្រូវផ្តល់ទិន្នន័យជូននិយ័តករជា Compact Disc ឬបញ្ជូនតាមខ្សែកាបដោយផ្ទាល់ មិនអោយយឺតជាង១៥ថ្ងៃបន្ទាប់ពីដំណាច់ខែនិមួយៗ ។

៥-៦ ក្នុងករណីដែលប្រតិបត្តិករម្ខាងមិនផ្តល់ទិន្នន័យ ឬក៏ពុំមានមូលហេតុសមរម្យចំពោះការអាក់ខានមិនផ្តល់ទិន្នន័យទេ និយ័តករអាចចាត់ទុកទិន្នន័យរបស់ភាគីម្ខាងទៀតជាការត្រឹមត្រូវ ។

៥-៧ ការទូទាត់ប្រាក់រវាងប្រព័ន្ធពីរត្រូវធ្វើឡើងតាមការឯកភាពជាគូភាគី ឧទាហរណ៍យ៉ាងយូរក្នុងរយៈពេល៣ខែម្តង តែបើសិនមានការតវ៉ាលើតួលេខ ត្រូវធ្វើយ៉ាងយូរ១៥ថ្ងៃក្រោយពីនិយ័តករបានបញ្ជាក់ថាត្រឹមត្រូវហើយ ។

៥-៨ ប្រតិបត្តិករត្រូវអនុវត្ត "គណនេយ្យផ្ទាល់" រវាងបណ្តាញបញ្ជូននិងបណ្តាញទទួល ។

## ៦. ការផាកពិន័យនិងថ្ងៃចូលជាធរមាន

៦-១ ប្រតិបត្តិករត្រូវបានផ្តន្ទាទោសតាមច្បាប់ព្រហ្មទ័ណ្ឌក្នុងករណីក្លែងបន្លំទិន្នន័យកត់ត្រាប្រចាំខែ និងអាចឈានទៅដល់ការដកហូតអាជ្ញាប័ណ្ណសំរាប់ធ្វើអាជីវកម្មផង ។

៦-២ ប្រតិបត្តិករមួយមានសិទ្ធផាកពិន័យជាការប្រាក់ ២% ក្នុងមួយខែឬក៏តាមការឯកភាពគ្នាជាទ្វេភាគីជាមុនចំពោះការយឺតយ៉ាវបង់ប្រាក់របស់ប្រតិបត្តករ ជាភាគីម្ខាងទៀតគិតចាប់ពីថ្ងៃដែលឯកភាពលើតួលេខហើយ ឬក៏ពីថ្ងៃដែលនិយ័តករបានបញ្ជាក់ថាត្រឹមត្រូវហើយ ។

៦-២ ប្រកាសនេះត្រូវចាប់អនុវត្តពីថ្ងៃទី១ឧសភាឆ្នាំ២០០២តទៅ ។

៦-៣ ប្រកាសណាពីមុនមកដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះចាត់ទុកជានិរាករណ៍ ។

រដ្ឋមន្ត្រី

សុខ អាន

**ចម្លងជូន :**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា -អគ្គលេខាធិការដ្ឋានរដ្ឋសភាជាតិ

-ទីស្តីការគណៈរដ្ឋមន្ត្រី -រាជកិច្ច

-ក្រសួងផែនការ -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

"ដើម្បីជ្រាបជាពតិមាន"

-គ្រប់អង្គភាពក្រោមឱវាទក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-គ្រប់ប្រតិបត្តិករ

"ដើម្បីអនុវត្តន៍" ។

-ឯកសារ - កាលប្បវត្តិ